មាត្រា ៨ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការនិង តំណាងក្រសួងនិងរដ្ឋលេខាធិការដ្ឋានដែលមានចែងក្នុងមាត្រា២ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះឲ្យបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០០០

| | |
|---|---|
| បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី | នាយករដ្ឋមន្ត្រី |
| ដើម្បីសុំហត្ថលេខា | ហត្ថលេខា និងត្រា |
| **រដ្ឋមន្ត្រីក្រសួងផែនការ** | **ហ៊ុន សែន** |
| **ឆាយ ថន** | |

★★★

## អនុក្រឹត្យលេខ ២៨ អនក្រ.បក
## ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា

****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- យោងតាមសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

### សំរេច

**មាត្រា ១ ._** បង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា ដែលមានសមាសភាពចំរុះមកពីបណ្តាក្រសួងស្ថាប័ននានា ដើម្បីជួយរាជរដ្ឋាភិបាល និងក្រសួងទេសចរណ៍ ក្នុងការគ្រប់គ្រងដឹកនាំការអភិវឌ្ឍន៍វិស័យទេសចរណ៍ទូទាំងប្រទេស ។

អាជ្ញាធរជាតិទេសចរណ៍កម្ពុជាមានអក្សរកាត់ថា “ អជទក ” ។

**មាត្រា ២ ._** អាជ្ញាធរជាតិទេសចរណ៍កម្ពុជា រួមមានសមាសភាព :

| | |
|---|---|
| ១-ឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាប្រធាន |
| ២-សម្តេចព្រះរាម **នរោត្តម បុប្ផាទេវី** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ជាអនុប្រធាន |
| ៣-ឯកឧត្តម **វណ្ណ ម៉ូលីវណ្ណ** ប្រធានអគ្គនាយកអាជ្ញាធរអប្សរា | ជាអនុប្រធាន |
| ៤-ឯកឧត្តម **វេង សេរីវុឌ្ឍ** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ជាអនុប្រធាន |

៥-ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការក្រសួងទេសចរណ៍ ជាសមាជិកប្រចាំការ

៦-ឯកឧត្តម ទ្រាំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាសមាជិក

៧-ឯកឧត្តម អ៊ុជ គឹមអន រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៨-ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋលេខាធិការក្រសួងពត៌មាន ជាសមាជិក

៩-ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

១០-ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

១១-ឯកឧត្តម ចន្ទ ស៊ុនអ៊ីវ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ជាសមាជិក

១២-ឯកឧត្តម ឆាន់ សាផាន់ រដ្ឋលេខាធិការក្រសួងបរិស្ថាន ជាសមាជិក

១៣-ឯកឧត្តម នឹម ថូត រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា ជាសមាជិក

១៤-ឯកឧត្តម កែវ សាផល អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាសមាជិក

១៥-ឯកឧត្តម សូ ម៉ារ៉ា អគ្គនាយកក្រសួងទេសចរណ៍ ជាអគ្គលេខាធិការ

មាត្រា ៣ ._ អាជ្ញាធរជាតិទេសចរណ៍កម្ពុជា មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

-ជំនួយអោយរាជរដ្ឋាភិបាលក្នុងការរៀបចំកសាងគោលនយោបាយ ផែនការអភិវឌ្ឍន៍ ការត្រួតពិនិត្យ និងសំរបសំរួលការងារអនុវត្ត ការអភិវឌ្ឍន៍វិស័យទេសចរណ៍ ។

-ត្រៀមការងារជូនរាជរដ្ឋាភិបាលដើម្បីសំរេចលើគំរោងអភិវឌ្ឍន៍ ឬវិនិយោគនានានៃវិស័យទេសចរណ៍ ។

-ណែនាំក្រសួងទេសចរណ៍ក្នុងការតាមដានបញ្ជាក់ និងឆ្លុះបញ្ចាំងលទ្ធផលនៃការអនុវត្តន៍គោលនយោបាយ សេចក្តីសំរេចចិត្ត ព្រមទាំងផែនការអនុវត្តទាំងឡាយដែលទាក់ទងដល់កិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍ ។

-កំណត់កំរិតអាទិភាព សំរាប់កិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍ និងការងារទីផ្សារទេសចរណ៍ ។

-សំរបសំរួលទំនាក់ទំនងស្ថាប័នសាធារណៈនានា គ្រឹះស្ថានឯកជននានា និងសមាគមទាំងឡាយដែលប្រកបអាជីកម្មវិស័យទេសចរណ៍ លើការអនុវត្តន៍ គោលនយោបាយ ផែនការ ដែលជាប់ទាក់ទងក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍ដោយឈរលើមូលដ្ឋាននៃផែនការអភិវឌ្ឍន៍ជាតិ ។

មាត្រា ៤ ._ អាជ្ញាធរជាតិទេសចរណ៍ មានសិទ្ធិទទួលនូវមធ្យោបាយសំរាប់វិស័យទេសចរណ៍ និង ប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល ឬគ្រឹះស្ថានឯកជននានា សំរាប់កិច្ចដំណើរការ ការងាររបស់ខ្លួន និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៥ ._ រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ [illegible] រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកនាំ

ជញ្ជូន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និង សម្តេច ឯកឧត្តមដែលមាននាមក្នុងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៧ ._** អនុក្រឹត្យនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ២៩ អនក្រ.តត

## ស្តីពីការបង្វែរឥណទាន

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ /០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខនរ/រកម/១២៩៩/១៥ចុះថ្ងៃទី២៥ខែធ្នូឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានចំណាយទៅតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០